ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៣៧៤ សរណន.កសក

# សារាចរណែនាំ
# ការអនុវត្តអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពី បមាណី និងការគ្រប់គ្រងសម្ភារៈកសិកម្ម

ក្នុងបំណងដ៏ខ្លាំងក្លា ជំរុញការអភិវឌ្ឍវិស័យកសិកម្មដែលជារចនាសម្ព័ន្ធស្នូលនៃខឿនសេដ្ឋកិច្ចជាតិ និងជាអាទិភាពដ៏មានសារៈសំខាន់មួយនៃគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច សំដៅពង្រីកផលិតកម្មកសិកម្ម ធានានូវនិរន្តរភាព សុវត្ថិភាពស្បៀងអាហារ និងធានាផ្គត់ផ្គង់វត្ថុធាតុដើមដល់ឧស្សាហកម្មកែច្នៃ និងបង្កើតការនាំចេញ រាជរដ្ឋាភិបាលបានកំណត់ និងដាក់ចេញនូវគោលនយោបាយលើកទឹកចិត្តដល់ផលិតកម្មកសិកម្មជាបន្តបន្ទាប់ តាមរយៈការផ្តល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីភោគៈ ដីសម្បទាន ការបើកទូលាយ និងការបន្ធូរបន្ថយពន្ធនាំចេញផលិតផលកសិកម្ម និងការនាំចូលមធ្យោបាយ និងសម្ភារៈផ្សេងៗបំរើឱ្យវិស័យកសិកម្ម។ ទន្ទឹមនឹងនេះដោយពិនិត្យឃើញនូវបាតុភាពអនាធិបតេយ្យក្នុងការផលិត ការនាំចូល ការធ្វើអាជីវកម្ម លក់ដូរសម្ភារៈកសិកម្មក្លែងបន្លំគុណភាព ខ្វះគុណភាព និងថ្នាំកសិកម្មហាមឃាត់ដែលបានបង្កផលប៉ះពាល់ដល់សុខុមាលភាពសង្គម ប៉ះពាល់ដល់បរិស្ថានសង្គម និងធម្មជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីបមាណី និងការគ្រប់គ្រងសម្ភារៈកសិកម្ម ក្នុងទិសដៅបង្កើតឱ្យមានបមាណី និងយន្តការគ្រប់គ្រងសម្ភារៈកសិកម្មមួយសមស្រប។

ដើម្បីអនុវត្តអនុក្រឹត្យរបស់រាជរដ្ឋាភិបាលខាងលើនេះឱ្យបានប្រកបដោយប្រសិទ្ធភាព និងទទួលបានលទ្ធផលជាវិជ្ជមានក្នុងការបំបាត់ ឬកាត់បន្ថយបាតុភាពអនាធិបតេយ្យខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំអនុវត្តដូចតទៅ :

## I. ការធ្វើអាជីវកម្មសម្ភារៈកសិកម្ម

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបាននិងកំពុងមានបំណងផលិត កែច្នៃ ស្តុក ផ្គត់ផ្គង់ វេចខ្ចប់ជាថ្មី នាំចេញ នាំចូល លក់ដុំ លក់រាយសម្ភារៈកសិកម្ម រួមមានថ្នាំកសិកម្ម ជីគីមី គ្រាប់ពូជ បំណែកពូជដំណាំ បសុឱសថ ចំណីសត្វ និងចំណីបន្ថែម ត្រូវមានលិខិតអនុញ្ញាតធ្វើអាជីវកម្មពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។



អាគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
200 Preah Norodom Sangkat Tonle Bassac Khan Chamkarmon B.V.D. Phnom Penh Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone (023) 211 351-211 352 Fax (855) 23-217 320

**I.១ ការដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម**

ក- សម្រាប់ការធ្វើអាជីវកម្ម ផលិត កែច្នៃ ស្តុក ផ្គត់ផ្គង់ វេចខ្ចប់ជាថ្មី នាំចេញ និងនាំចូលសម្ភារៈកសិកម្ម រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ " នាយកដ្ឋាននីតិកម្មកសិកម្ម " តាមបែបបទដូចខាងក្រោម :

១- ពាក្យសុំមានបិទតែម ( មានគំរូ) ចំនួន ២ ច្បាប់

២- ប្រវត្តិរូបសង្ខេបរបស់អាជីវករមានបិទរូបថត ៤x៦ មានបញ្ជាក់ពីរដ្ឋបាលឃុំ សង្កាត់ ចំនួន ២ ច្បាប់

៣- អត្តសញ្ញាណប័ណ្ណថតចម្លង ចំនួន ២ ច្បាប់

៤- កិច្ចសន្យានៃការធ្វើអាជីវកម្ម ( មានគំរូ ) ចំនួន ២ ច្បាប់

៥- លិខិតបញ្ជាក់ពីទីតាំងធ្វើអាជីវកម្មចេញដោយរដ្ឋបាលឃុំ សង្កាត់ ចំនួន ២ ច្បាប់

៦- លិខិតអនុញ្ញាតឱ្យដាក់ទីតាំងស្តុកចេញដោយក្រសួងបរិស្ថាន( សម្រាប់ថ្នាំកសិកម្ម ) ចំនួន ២ ច្បាប់

៧- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មចេញដោយក្រសួងពាណិជ្ជកម្ម ចំនួន ២ ច្បាប់

ខ- សម្រាប់ការធ្វើអាជីវកម្មលក់ដុំ លក់រាយសម្ភារៈកសិកម្ម រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង តាមបែបបទដូចខាងក្រោម :

១- ពាក្យសុំមានបិទតែម ( មានគំរូ ) ចំនួន ២ ច្បាប់

២- ប្រវត្តិរូបសង្ខេបរបស់អាជីវករមានបិទរូបថត ៤ x ៦ មានបញ្ជាក់ពីរដ្ឋបាលឃុំ សង្កាត់ ចំនួន ២ ច្បាប់

៣- អត្តសញ្ញាណប័ណ្ណថតចម្លង ចំនួន ២ ច្បាប់

៤- កិច្ចសន្យានៃការធ្វើអាជីវកម្ម ( មានគំរូ ) ចំនួន ២ ច្បាប់

៥- លិខិតអនុញ្ញាតដាក់ទីតាំងស្តុក ចេញដោយមន្ទីរបរិស្ថានខេត្ត ក្រុង
( សម្រាប់តែថ្នាំកសិកម្ម ) ។ ចំនួន ២ ច្បាប់

**I.២ សមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្ម**

ក- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬបដិសេធពាក្យសុំធ្វើអាជីវកម្ម ផលិត កែច្នៃ ស្តុក ផ្គត់ផ្គង់ និងវេចខ្ចប់ជាថ្មី នាំចេញ នាំចូលសម្ភារៈកសិកម្ម សម្រាប់ធ្វើពាណិជ្ជកម្មក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលក្រសួងបានទទួលសំណុំលិខិតជាផ្លូវការគ្រប់គ្រាន់ និងត្រឹមត្រូវ ។

ខ- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង នឹងត្រូវផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬបដិសេធពាក្យសុំធ្វើអាជីវកម្មដល់អាជីវករលក់ដុំ លក់រាយសម្ភារៈកសិកម្មក្នុងរយៈពេលយ៉ាងយូរ ៧ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង បានទទួលសំណុំលិខិតជាផ្លូវការ គ្រប់គ្រាន់ និងត្រឹមត្រូវ។

## II. ការចុះបញ្ជិកាសម្ភារៈកសិកម្ម

ប្រភេទសម្ភារៈកសិកម្មដែលរួមមាន ថ្នាំកសិកម្ម ជីគីមី គ្រាប់ពូជមានវិញ្ញាបនបត្រ បំណែកពូជដំណាំ ចំណីសត្វ ឬចំណីបន្ថែម អាចអនុញ្ញាតឱ្យផលិត នាំចូលសម្រាប់ធ្វើពាណិជ្ជកម្ម លក់ដូរ និងប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែសម្ភារៈកសិកម្មទាំងនោះបានចុះបញ្ជិកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយ ។

ប្រភេទសម្ភារៈកសិកម្មដែលមានរូបមន្ត ឬឈ្មោះពាណិជ្ជកម្មខុសគ្នា ត្រូវធ្វើការចុះបញ្ជិកាផ្សេងគ្នា។ រូបវន្តបុគ្គល ឬនីតិបុគ្គល មានបំណងផលិតគ្រាប់ពូជមានវិញ្ញាបនបត្រ ឬបំណែកពូជដំណាំដែលបានចុះបញ្ជិកាហើយដើម្បីធ្វើពាណិជ្ជកម្ម ត្រូវអនុវត្តតាមបច្ចេកវិទ្យាដែលបានណែនាំសម្រាប់ការផលិត និងដំណើរការរៀបចំទុកដាក់គ្រាប់ពូជទាំងនោះ ។

### II.១ ការដាក់ពាក្យសុំចុះបញ្ជិកាសម្ភារៈកសិកម្ម

រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវដាក់ពាក្យសុំធ្វើការចុះបញ្ជិកាសម្ភារៈកសិកម្មនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ " នាយកដ្ឋាននីតិកម្មកសិកម្ម " តាមបែបបទដូចខាងក្រោម :

| | |
|---|---|
| ១- ពាក្យសុំចុះបញ្ជិកា ( មានគំរូ ) | ចំនួន ២ ច្បាប់ |
| ២- លិខិតថតចម្លងការអនុញ្ញាតធ្វើអាជីវកម្ម ( បើសិនជាមាន ) | ចំនួន ២ ច្បាប់ |
| ៣- ពតិមានបច្ចេកទេសស្តីពីផលិតផល ជាភាសាខ្មែរ និងអង់គ្លេស | ចំនួន ២ ច្បាប់ |
| ៤- ការធានាគុណភាព ឬវិញ្ញាបនបត្របញ្ជាក់គុណភាពពីរោងចក្រផលិត | ចំនួន ២ ច្បាប់ |
| ៥- គំរូសម្ភារៈវេចខ្ចប់ និងស្លាកសញ្ញាជាអក្សរខ្មែរ | ចំនួន ២ សន្លឹក |
| ៦- គំរូសំណាកនៃផលិតផល ដើម្បីវិភាគ ឬសិក្សាពិសោធន៍ | ចំនួន២ ឯកតា |

### II.២ សមត្ថកិច្ចក្នុងការផ្តល់វិញ្ញាបនបត្រចុះបញ្ជិកាសម្ភារៈកសិកម្ម

ក-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តល់វិញ្ញាបនបត្រចុះបញ្ជិកាសម្ភារៈកសិកម្ម ដែលសមស្របសម្រាប់លក់ដូរ និងប្រើប្រាស់ ជូនរូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលសំណុំលិខិតជាផ្លូវការគ្រប់គ្រាន់ និងត្រឹមត្រូវ ។

ខ-ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានសិទ្ធិជំទាស់មិនធ្វើការចុះបញ្ជិកានូវផលិតផលសម្ភារៈកសិកម្មណាដែលពិនិត្យឃើញថា :

- អាចមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន
- ស្ថិតក្នុងបញ្ជីហាមប្រើប្រាស់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខូចគុណភាព ឬក្លែងបន្លំគុណភាព ប្រភេទ ឬបរិមាណធាតុសកម្មខុសពីប្រភេទ ឬបរិមាណធាតុសកម្ម

បញ្ជាក់លើស្លាកសញ្ញា ឬឯកសារបច្ចេកទេស

- ពុំមានការវេចខ្ចប់ត្រឹមត្រូវ និងមានស្លាកសញ្ញា និងពតិមានបច្ចេកទេសច្បាស់លាស់ជាភាសាខ្មែរ សមស្របតាមគោលការណ៍ដែលក្រសួងបានកំណត់
- គ្មានប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការប្រើប្រាស់ ឬគ្មានផលប្រយោជន៍ដល់កសិករ
- ជាប្រភេទគ្រាប់ពូជដែលធ្វើការបំរែបំរួលសែន (GMO)
- ជាផលិតផលនាំចូលដោយគ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## II.៣ បញ្ជិកាថ្នាំកសិកម្ម

ចំពោះថ្នាំកសិកម្មដែលជាប្រភេទសម្ភារៈកសិកម្មអាចបង្កគ្រោះថ្នាក់ និងមានផលប៉ះពាល់ខ្លាំងជាងគេដល់សុខភាពមនុស្ស សត្វ បរិស្ថានសង្គម និងធម្មជាតិ គឺមានបែបបទ និងលក្ខខណ្ឌនៃការចុះបញ្ជិកាដោយឡែកដូចខាងក្រោម :

១- <u>បញ្ជិកាបណ្តោះអាសន្ន</u> : បញ្ជិកានេះត្រូវធ្វើចំពោះគ្រប់មុខថ្នាំកសិកម្មណាដែលមានចែងក្នុងប្រកាសអនុញ្ញាតឱ្យប្រើប្រាស់ជាបណ្តោះអាសន្នរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយដែលកំពុងត្រូវបានចរាចរលក់នៅតាមទីផ្សារ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តល់បញ្ជិកាបណ្តោះអាសន្ន ដែលមានសុពលភាពរយៈពេល០១ឆ្នាំ ប្រសិនបើថ្នាំកសិកម្មនោះមានឯកសារអះអាងអំពីប្រសិទ្ធភាព និងសុវត្ថិភាពគ្រប់គ្រាន់ និងត្រឹមត្រូវ។ បញ្ជិកានេះនឹងត្រូវបានផ្ទេរទៅជាបញ្ជិកាពេញលេញ ក្នុងរយៈពេលមួយឆ្នាំក្រោយ ប្រសិនបើអ្នកស្នើសុំចុះបញ្ជិកាបានបំពេញនូវគ្រប់តម្រូវការបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការសុំពន្យាសម្រាប់រយៈពេលមួយឆ្នាំអាចអនុញ្ញាតបានក្នុងករណីដែលមានមូលហេតុសមស្រប ។

ក្រោយពីទទួលបានបញ្ជិកាបណ្តោះអាសន្នហើយ ម្ចាស់ផលិតផលថ្នាំកសិកម្មនោះអាចស្នើសុំនាំចូល ឬផលិតក្នុងបរិមាណកំណត់មួយ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណងសិក្សាទីផ្សារ។

២- <u>បញ្ជិកាស្ថិតក្នុងលក្ខខណ្ឌ</u> : បញ្ជិកានេះត្រូវធ្វើចំពោះថ្នាំកសិកម្មណា ដែលត្រូវបានស្នើសុំចុះបញ្ជិកាលើកដំបូង តែត្រូវផ្តល់បន្ថែមនូវទិន្នន័យ ឬលក្ខខណ្ឌចាំបាច់ដទៃទៀតតាមតម្រូវការបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ បញ្ជិកានេះនឹងត្រូវបានផ្ទេរទៅជាបញ្ជិកាពេញលេញក្នុងរយៈពេលមួយឆ្នាំក្រោយ ប្រសិនបើអ្នកស្នើសុំចុះបញ្ជិកាបានបំពេញនូវគ្រប់តម្រូវការបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការសុំពន្យាសម្រាប់រយៈពេលមួយឆ្នាំអាចអនុញ្ញាតបានក្នុងករណីដែលមានមូលហេតុសមស្រប ។

៣-<u>បញ្ជិកាពេញលេញ</u> : បញ្ជិកានេះត្រូវធ្វើចំពោះថ្នាំកសិកម្មណា ដែលអ្នកសុំចុះបញ្ជិកាបានបំពេញនូវគ្រប់តម្រូវការបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

វិញ្ញាបនបត្រចុះបញ្ជិកាព្រមទាំងលេខបញ្ជិកានឹងត្រូវចេញជូនដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ក្នុងករណីដែលគ្មានការដកហូត ឬលុបចោលណាមួយនោះ វិញ្ញាបនបត្រចុះបញ្ជិកាពេញលេញមានសុពលភាពរយៈពេល០៣ឆ្នាំ ។ ការចុះបញ្ជិកាជាថ្មីអាចនឹងទទួលបានក្រោយពីក្រសួងបានទទួលនូវពាក្យស្នើសុំ និងទិន្នន័យបន្ថែម ។ ការខកខានក្នុងការសុំចុះបញ្ជិកាជាថ្មី ពេលសុពលភាពត្រូវបានបញ្ចប់ មុខថ្នាំកសិកម្មនោះពុំអាចធ្វើការនាំចូល និងធ្វើចរាចរលក់ដូរបានឡើយ ។

ក្នុងរយៈពេលបីខែយ៉ាងយូរមុនផុតកំណត់សុពលភាពនៃវិញ្ញាបនបត្រចុះបញ្ជិកាពេញលេញ សាមីជន ឬក្រុមហ៊ុន ម្ចាស់ផលិតផល ត្រូវបំពេញសំណុំលិខិតចុះបញ្ជិកាជាថ្មីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ " នាយកដ្ឋានទីតិកម្មកសិកម្ម " ដូចខាងក្រោម :

| | |
|---|---|
| - ពាក្យសុំចុះបញ្ជិកាជាថ្មី ( មានគំរូ ) | ចំនួន ២ ច្បាប់ |
| - គំរូសំណាកនៃផលិតផលដើម្បីធ្វើការវិភាគ | ចំនួន ២ ច្បាប់ |
| - វិញ្ញាបនបត្របញ្ជិកាចាស់ | ចំនួន ១ ច្បាប់ |

៤-<u>ការអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ពិសោធន៍</u> : គឺជាការអនុញ្ញាត ដើម្បីនាំចូលថ្នាំកសិកម្មណាដែលមិនទាន់បានចុះបញ្ជិកា សម្រាប់យកមកប្រើប្រាស់ក្នុងគោលបំណងសិក្សាស្រាវជ្រាវប៉ុណ្ណោះ ។

## III. ការនាំចេញ នាំចូលសម្ភារៈកសិកម្ម

រូបវន្តបុគ្គល ឬនីតិបុគ្គលអាចទទួលបាននូវលិខិតអនុញ្ញាតឱ្យធ្វើការនាំចូល ឬនាំចេញនូវមុខសម្ភារៈណាមួយនោះ លុះណាតែរូបវន្តបុគ្គល ឬនីតិបុគ្គលនោះបានទទួលលិខិតអនុញ្ញាតធ្វើអាជីវកម្ម ហើយមុខសម្ភារៈកសិកម្មដែលស្នើសុំនាំចូល ឬនាំចេញនោះ ត្រូវបានទទួលឱ្យចុះបញ្ជិកា និងទទួលបានវិញ្ញាបនបត្រចុះបញ្ជិកាត្រឹមត្រូវជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### III.១ ការដាក់ពាក្យសុំលិខិតអនុញ្ញាតនាំចេញ នាំចូលសម្ភារៈកសិកម្ម

១/សំណុំលិខិតស្នើសុំលិខិតអនុញ្ញាតឱ្យនាំចូលមាន :

| | |
|---|---|
| - ពាក្យសុំ ( មានគំរូ ) | ចំនួន ២ ច្បាប់ |
| - លិខិតអនុញ្ញាតធ្វើអាជីវកម្មថតចម្លង | ចំនួន ២ ច្បាប់ |
| - វិញ្ញាបនបត្រចុះបញ្ជិកាថតចម្លង | ចំនួន ២ ច្បាប់ |
| - វិញ្ញាបនបត្រអនាម័យផលិតផលចេញដោយប្រទេសនាំចេញ | ចំនួន ២ ច្បាប់ |

២/សំណុំលិខិតស្នើសុំលិខិតអនុញ្ញាតនាំចេញមាន :

- ពាក្យសុំ ( មានគំរូ ) ចំនួន ២ ច្បាប់
- លិខិតអនុញ្ញាតធ្វើអាជីវកម្មថតចម្លង ចំនួន ២ ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជិកាថតចម្លង ចំនួន ២ ច្បាប់

**III.២ សមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាតនាំចេញ នាំចូល**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តល់នូវសេចក្តីសម្រេចរបស់ខ្លួន ចំពោះការផ្តល់ ឬមិនផ្តល់លិខិតអនុញ្ញាតនាំចេញ នាំចូលក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានសំណុំលិខិតគ្រប់គ្រាន់ និងត្រឹមត្រូវជាផ្លូវការពីអ្នកស្នើសុំ ។

បរិមាណនៃថ្នាំកសិកម្មដែលអាចអនុញ្ញាតឱ្យធ្វើការនាំចូល ត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើលក្ខខណ្ឌទុកដាក់ លទ្ធភាពឃ្លាំងស្តុករបស់អ្នកស្នើសុំ តម្រូវការក្នុងស្រុក និងដើម្បីចៀសវាងផលប៉ះពាល់ដល់បរិស្ថាននៅពេលត្រូវការកម្ទេចចោលនូវថ្នាំកសិកម្មដែលផុតកំណត់ការប្រើប្រាស់ ។

ការនាំចេញ នាំចូលនូវគ្រាប់ពូជ និង បំណែកពូជដំណាំ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃការត្រួតពិនិត្យភូតគាមអនាម័យ ។

លិខិតអនុញ្ញាតនាំចេញ នាំចូលមានសុពលភាពរយៈពេល ០១ឆ្នាំ គិតចាប់ពីថ្ងៃដែលចេញលិខិតអនុញ្ញាតនោះ ។

## IV.ការដកហូត ឬលុបចោលលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬវិញ្ញាបនបត្រចុះបញ្ជិកាសម្ភារៈកសិកម្ម

**IV.១ ការដកហូត ឬលុបចោលលិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារៈកសិកម្ម**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិដកហូត ឬលុបចោលលិខិតអនុញ្ញាតធ្វើអាជីវកម្មក្នុងករណី :

- អ្នកកាន់លិខិតអនុញ្ញាតមិនគោរពតាមកិច្ចសន្យានៃការធ្វើអាជីវកម្មរបស់ខ្លួន ឬបានបំពានលើសារាចរណែនាំនេះ ឬបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងអនុក្រឹត្យ ស្តីពីបមាណីនិងការគ្រប់គ្រងសម្ភារៈកសិកម្ម
- ទីតាំងគ្រឹះស្ថានធ្វើអាជីវកម្មមានការផ្លាស់ប្តូរ ហើយមិនបានជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមុន ឬយ៉ាងយូរ១០ ថ្ងៃក្រោយពីការផ្លាស់ប្តូរ ។

IV.២ ការដកហូត ឬលុបចោលវិញ្ញាបនបត្រចុះបញ្ជិកាសម្ភារៈកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិដកហូត ឬលុបចោលវិញ្ញាបនបត្រចុះបញ្ជិកាសម្ភារៈកសិកម្មក្នុងករណី :

- លទ្ធផលនៃការស្រាវជ្រាវ បានបង្ហាញពីផលប៉ះពាល់ធ្ងន់ធ្ងរជាយថាហេតុដល់សុខភាពមនុស្ស សត្វ បរិស្ថាន បណ្តាលមកពីឥទ្ធិពលនៃការប្រើប្រាស់មុខសម្ភារៈកសិកម្មនោះរយៈពេលយូរឆ្នាំ
- មុខសម្ភារៈកសិកម្មដែលបានផលិត នាំចូល និងធ្វើអាជីវកម្មលក់ដូរខុសពីសម្ភារៈកសិកម្មដែលបានចុះបញ្ជិកា ទាំងគុណភាព ការវេចខ្ចប់ ស្លាកសញ្ញា ។ល។
- អ្នកកាន់វិញ្ញាបនបត្រចុះបញ្ជិកាមិនបានគោរពតាមកិច្ចសន្យានៃការធ្វើអាជីវកម្មរបស់ខ្លួន ឬបានបំពានលើសារាចរណែនាំនេះ ឬបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងអនុក្រឹត្យលេខ៦៩ អនក្រ.បក ស្តីពីបមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម ។

IV.៣ ការតវ៉ា

អាជីវករមានសិទ្ធិតវ៉ាមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះសេចក្តីសម្រេចនៃការដកហូត ឬលុបចោលលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬ វិញ្ញាបនបត្រចុះបញ្ជិកា ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីសម្រេច ។

## V. ការវេចខ្ចប់ និងស្លាកសញ្ញា

V.១ ថ្នាំកសិកម្ម

- សម្ភារៈវេចខ្ចប់ថ្នាំកសិកម្ម ត្រូវឆ្លើយតបទៅនឹងបមាណីអន្តរជាតិ មានភាពជាប់មាំ ធានាបានចំពោះរាល់ការលើកដាក់ កាន់យូរ ទុកដាក់ មានលក្ខណៈអាចការពារការចុះអន់គុណភាព ការស្រកមាឌ ការប្តូរទម្ងន់ ឬក៏ការខូចខាតដទៃទៀត
- ការវេចខ្ចប់ជាថ្មី ឬការផ្ទេរថ្នាំកសិកម្មពីសម្ភារៈវេចខ្ចប់ដើមទៅក្នុងសម្ភារៈវេចខ្ចប់ថ្មីត្រូវហាមឃាត់ ។ ក្នុងករណីចាំបាច់ ការវេចខ្ចប់ជាថ្មី ឬការផ្ទេរថ្នាំកសិកម្ម ពីសម្ភារៈវេចខ្ចប់ដើមទៅក្នុងសម្ភារៈវេចខ្ចប់ថ្មីនេះអាចធ្វើទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  - ១- សម្ភារៈវេចខ្ចប់ជាថ្មី ដែលបានការអនុញ្ញាតរួចហើយនោះ ត្រូវឆ្លើយតបតាមបមាណីនៃការវេចខ្ចប់ ដូចមានចែងក្នុងចំណុច V.១ កថាខ័ណ្ឌ១ នៃសារាចរណែនាំនេះ ។
  - ២- ថ្នាំកសិកម្មដែលត្រូវវេចខ្ចប់ជាថ្មីនោះ បានចុះបញ្ជិការួចហើយនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- ការផ្ទេរ ឬចែកថ្នាំកសិកម្មណាមួយ ទៅក្នុងសម្ភារៈវេចខ្ចប់ចំណីអាហារ ឬភេសជ្ជៈ ត្រូវហាមឃាត់

- ស្លាកសញ្ញាសម្ភារះវេចខ្ចប់ថ្នាំកសិកម្ម ត្រូវបិទភ្ជាប់ឱ្យជាប់ល្អ ឬវាយពុម្ពពីលើ នូវស្លាកសញ្ញាជាអក្សរខ្មែរងាយយល់ សមស្របតាមលក្ខខណ្ឌកំណត់ដូចខាងក្រោម :

១- ឈ្មោះទូទៅ និងឈ្មោះពាណិជ្ជកម្មថ្នាំកសិកម្ម ( Product Name ) ។

២- ប្រភេទថ្នាំកសិកម្ម (Type of Pesticide ) ។

៣- ឈ្មោះប្រទេសផលិត ( Origin country ) ។

៤- សមាសភាគនៃធាតុសកម្ម ( Active ingredient and its content ) ។

៥- ប្រភេទនៃទម្រង់ផ្សំ ( Type of Formulation ) ។

៦- ទម្ងន់ ឬចំណុះ ( Net content ) ។

៧- លេខឡូតិ៍ ( Lot number ) ។

៨- ថ្ងៃខែឆ្នាំផលិត និងថ្ងៃខែឆ្នាំផុតកំណត់ការប្រើប្រាស់ ( Manufacturing date and Expiring date ) ។

១០- លេខបញ្ជិកា ( Registration Number ) ។

១១- របៀបប្រើប្រាស់ ( directions for use ) :

- ប្រភេទដំណាំ ដែលត្រូវប្រើប្រាស់ ( Target Crop )
- ប្រភេទកត្តាចង្រៃដែលត្រូវកំចាត់ ( Target insects, diseases, weeds )
- កម្រិតប្រើ ( Dose rates )
- ភាពលាយបានជាមួយថ្នាំ កសិកម្មដទៃទៀត ( Compatibility )
- វិធីសាស្ត្រ និងពេលវេលានៃការប្រើប្រាស់(Methods and timing of application )
- រយៈពេលរង់ចាំ មុនពេលប្រមូលផល ( Pre-harvest intervals )
- **ការណែនាំអំពីការសង្គ្រោះបន្ទាន់** ( First-aid instructions ) ។

១២- សរសេរជាអក្សរធំៗថា " ទុកឱ្យផុតពីដៃក្មេង " ( Keep out of reach of Children ) ។

១៣- របៀបទុកដាក់ ។

១៤- និមិត្តសញ្ញាបង្ការគ្រោះថ្នាក់ ( Pictograms ) ។

១៥- ថ្នាំបន្សាប ( Antidote ) ។

- ចំពោះស្លាកសញ្ញានៃសម្ភារះវេចខ្ចប់ថ្នាំកសិកម្ម ដែលមានចំណុះតិចជាង ៥០០មិល្លីលីត្រ ឬ៥០០ក្រាម ត្រូវភ្ជាប់បន្ថែមបរិយាយប័ណ្ណ ( Leaflet ) ផ្តល់ពត៌មានលំអិតអំពីផលិតផលនោះ ដែលមានលក្ខណៈអាចបិទជាប់នឹងផលិតផល ចងភ្ជាប់នឹងផលិតផល ឬអាចដាក់ដោយឡែកពីផលិតផល

- ពណ៌ និងការបោះពុម្ពអត្ថបទលើស្លាកសញ្ញា :

១- អត្ថបទលើស្លាកសញ្ញា ត្រូវសរសេរដោយប្រើទឹកពណ៌ខ្មៅលើផ្ទៃក្រដាសពណ៌ស ។

២- ពណ៌ក្រហមអាចប្រើសម្រាប់ឃ្លាសំខាន់ៗដូចជា : ចំណងជើង សញ្ញាគ្រោះថ្នាក់ និងការប្រុងប្រយ័ត្ន ។

៣- វន្ត (Trace) ពណ៌ក្រហម និង សញ្ញាក្បាលខ្មោច ប្រើសំគាល់គ្រោះថ្នាក់ខ្លាំង ពណ៌លឿង និងសញ្ញាខ្វែង ប្រើសំគាល់គ្រោះថ្នាក់មធ្យម និងពណ៌ខៀវ សំគាល់គ្រោះថ្នាក់ខ្សោយ ។

៤- ចៀសវាងសរសេរអត្ថបទបញ្ឈរ បញ្ឆៀង ឬបោះពុម្ពត្រួតលើគ្នា ។

## V.២ ជីគីមី

### - ជីគីមីរឹង :

១- *សម្ភារៈវេចខ្ចប់* :

ជីគីមីដែលនាំចូល ផលិតនៅក្នុងប្រទេស សម្រាប់លក់ ត្រូវតែប្រកក្នុងសម្ភារៈវេចខ្ចប់ដែលមិនរហែកធ្លុះធ្លាយ ធន់នឹងអាកាសធាតុ មានភាពជាប់មាំល្អ ដើម្បីធានាគុណភាព ព្រមទាំងសម្រួលដល់ការដឹកជញ្ជូន ស្តុកទុក និងប្រើប្រាស់ ។

២- *ស្លាកសញ្ញា* :

ជីគីមីនាំចូល ឬផលិតក្នុងប្រទេស ត្រូវតែមានស្លាកសញ្ញាផ្តល់ពត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ជាអក្សរខ្មែរ ងាយអាន ហើយមិនងាយលុប និងត្រូវបញ្ជាក់អំពី :

- ភាគរយនៃសមាសធាតុចិញ្ចឹម ( N-P-K ) និងធាតុផ្សេងៗ
- លេខបញ្ជិកា
- ឈ្មោះប្រទេសផលិត
- ទម្ងន់ ។

៣- *ការវេចខ្ចប់ជាថ្មី* :

ការវេចខ្ចប់ជីគីមីជាថ្មីទៅក្នុងថង់តូចៗសម្រាប់លក់អាចប្រព្រឹត្តទៅបាន លុះត្រាតែមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ជីគីមីដែលវេចខ្ចប់ថ្មី ត្រូវវេចខ្ចប់នៅក្នុងថង់ប្លាស្ទិចថ្នាក្រាស់ ហើយភ្ជិតយ៉ាងត្រឹមត្រូវ ដែលធន់នឹងការយួរ និងដឹកជញ្ជូន។ កញ្ចប់ត្រូវមានស្លាកសញ្ញាជាអក្សរខ្មែរ បោះពុម្ពលើក្រដាសមួយសន្លឹកដាក់ក្នុងថង់ ដោយមានពត៌មានដូច ខាងក្រោម :

- ឈ្មោះ និងអាសយដ្ឋានអ្នកវេចខ្ចប់ជាថ្មី
- ឈ្មោះ និងសមាសភាគធាតុចិញ្ចឹម
- ទម្ងន់
- ថ្ងៃ ខែ ឆ្នាំវេចខ្ចប់ជាថ្មី ។

- **ជីគីមីរាវ :**

១- ការវេចខ្ចប់ :

ជីគីមីរាវទាំងនោះ ត្រូវវេចខ្ចប់ដោយសម្ភារៈវេចខ្ចប់ ដែលមានលក្ខណៈអាចការពារការចុះអន់គុណភាព ការស្រកមាឌ ការប្តូរទម្ងន់ ឬក៏ការខូចខាតដទៃទៀត ហើយត្រូវមានលក្ខណៈងាយស្រួលក្នុងការបោះពុម្ពពីលើដប ឬបិទភ្ជាប់ ស្លាកសញ្ញា ។

២- ស្លាកសញ្ញា :

ត្រូវបញ្ជាក់អំពី :

- ឈ្មោះផលិតផល ( Product Name )
- សមាសភាគនៃធាតុចិញ្ចឹម ( Content of nutrients )
- ឈ្មោះប្រទេសផលិត ( Name of Origin country )
- ទម្ងន់ ឬចំណុះ ( Net Content )
- លេខឡូតិ៍ ( Lot Number )
- លេខបញ្ជិកា ( Registration Number )
- ថ្ងៃខែឆ្នាំផលិត និងផុតកំណត់ការប្រើប្រាស់ ( Manufacturing Date and Expiring Date )
- របៀបប្រើ ( directions for use )
  - ◆ ប្រភេទដំណាំដែលត្រូវប្រើប្រាស់ ( Target Crops )
  - ◆ កម្រិតប្រើ ( Dose Rate )
  - ◆ វិធីសាស្ត្រ និងពេលវេលានៃការប្រើប្រាស់ ( Methods and timing of application )
- កំណត់សំគាល់ផ្សេងៗ : ( Remarks )
  - ◆ សរសេរជាអក្សរធំៗថា " ទុកឱ្យផុតពីដៃក្មេង " ( Keep out of reach of Children )
  - ◆ របៀបទុកដាក់ ( Storage )
  - ◆ ភាពលាយបានជាមួយជីគីមី ឬថ្នាំកសិកម្មដទៃទៀត ( Compatibility ) ។

## V.៣ គ្រាប់ពូជ និងបំណែកពូជដំណាំ

១- សម្ភារៈវេចខ្ចប់ :

សម្ភារៈវេចខ្ចប់ ត្រូវមានភាពជាប់មាំបិទភ្ជិតត្រឹមត្រូវ សម្រាប់ច្រក ខ្ចប់ ឬផ្ទុកគ្រាប់ពូជ និងបំណែកពូជដំណាំ ដើម្បីរក្សាគុណភាពគ្រាប់ពូជ និងបំណែកពូជដំណាំ ។

២- ស្លាកសញ្ញា :

ស្លាកសញ្ញា ត្រូវសរសេរជាអក្សរខ្មែរច្បាស់ៗ ងាយយល់ ងាយអាន ដោយបោះពុម្ពលើ បិទឬកិបនឹង

សម្ភារៈវេចខ្ចប់ ហើយត្រូវផ្តល់ពត៌មានដូចខាងក្រោម :

១- ឈ្មោះ និងអាសយដ្ឋានអ្នកផលិត ។

២- ប្រភេទគ្រាប់ពូជ ។

៣- ឈ្មោះពូជ ( ឈ្មោះទូទៅ និង Botanique ) ។

៤- ចំណាត់ថ្នាក់ពូជ ( ពូជមានវិញ្ញាបនបត្រ ពូជគ្រឹះ ឬពូជបង្កាត់ ... ) ។

៥- កាលបរិច្ឆេទ / ឆ្នាំប្រមូលផល ។

៦- លេខវិញ្ញាបនបត្រ ឬលេខឡូតិ៍គ្រាប់ពូជ ។

៧- ភាគរយភាពសុទ្ធ ។

៨- ភាគរយដំណុះ ។

៩- ភាគរយសំណើម ។

១០- ទម្ងន់ និងទម្ងន់សរុប ។

១១- ប្រទេសដើម ប្រសិនបើជាគ្រាប់ពូជនាំចូល ។

១២- នៅលើស្លាកសញ្ញាត្រូវសរសេរបម្រាម " មិនត្រូវប្រើសម្រាប់ធ្វើជាម្ហូបអាហារមនុស្ស សត្វ " ប្រសិនបើគ្រាប់ពូជទាំងនោះ ត្រូវបានលាយជាមួយថ្នាំកសិកម្ម ព្រមទាំងបញ្ជាក់ប្រាប់ឈ្មោះថ្នាំកសិកម្មទាំងនោះផង ឬ " មិនអាចទុកពូជបន្ត " បើសិនពូជនោះជាពូជបង្កាត់ ( អ៊ីប្រ៊ីត ) ។

## V.៤ ចំណីសត្វ និងចំណីបន្ថែម

*១- សម្ភារៈវេចខ្ចប់ :*

ចំណីសត្វដែលនាំចូល ឬផលិតនៅក្នុងប្រទេសសម្រាប់លក់ ត្រូវតែច្រកក្នុងសម្ភារៈវេចខ្ចប់ដែលមិនរហែកធ្លុះធ្លាយ ធន់នឹងអាកាសធាតុ មានភាពជាប់មាំល្អ ដើម្បីធានាគុណភាព ព្រមទាំងសម្រួលដល់ការដឹកជញ្ជូន ស្តុកទុក និងប្រើប្រាស់ ។

*២-ស្លាកសញ្ញា :*

ចំណីសត្វនាំចូល ឬផលិតក្នុងប្រទេស ត្រូវតែមានស្លាកសញ្ញាផ្តល់ពត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ជាអក្សរខ្មែរងាយអាន ហើយមិនងាយលុប និងត្រូវបញ្ជាក់អំពី :

- ឈ្មោះផលិតផល
- សមាសភាគនៃសារធាតុចិញ្ចឹម និងធាតុផ្សេងៗ
- លេខបញ្ជិកា
- ឈ្មោះប្រទេសផលិត
- លេខឡូតិ៍

- របៀបប្រើប្រាស់
- របៀបទុកដាក់
- ថ្ងៃខែឆ្នាំផលិត និងថ្ងៃខែឆ្នាំផុតកំណត់ការប្រើប្រាស់
- ទម្ងន់សុទ្ធ (Net weight) ។

## VI.ការបោះចោល ការបំផ្លាញចោលនូវសំណល់ ឬសម្ភារៈវេចខ្ចប់ និងថ្នាំកសិកម្មដែលឈប់ឱ្យប្រើប្រាស់

- រាល់ការបោះចោល ការបំផ្លាញចោលនូវសំណល់ ឬសម្ភារៈវេចខ្ចប់ ឬថ្នាំកសិកម្មដែលឈប់ឱ្យប្រើប្រាស់របស់អាជីវករ ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដោយមានការឯកភាពពីក្រសួងបរិស្ថាន
- វិធីសាស្ត្រនៃការបោះចោល ការបំផ្លាញចោលនូវសំណល់ ឬសម្ភារៈវេចខ្ចប់ ឬថ្នាំកសិកម្មដែលឈប់ឱ្យប្រើប្រាស់ ត្រូវអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដោយមានការឯកភាពពីក្រសួងបរិស្ថាន
- រាល់ការចំណាយផ្សេងៗក្នុងការបោះចោល ឬបំផ្លាញចោលនូវសំណល់ ឬសម្ភារៈវេចខ្ចប់ ឬថ្នាំកសិកម្មដែលឈប់ឱ្យប្រើប្រាស់ ជាបន្ទុករបស់អាជីវករ ។

## VII.ការទុកដាក់ និងការដាក់តាំងលក់ថ្នាំកសិកម្ម

### VII.១ ការទុកដាក់ថ្នាំកសិកម្ម

- របៀប និងលក្ខខណ្ឌទុកដាក់ថ្នាំកសិកម្ម ត្រូវអនុវត្តដូចខាងក្រោម ៖

ក- <u>របៀបទុកដាក់</u> ៖

១- ត្រូវរក្សាថ្នាំកសិកម្មក្នុងសម្ភារៈវេចខ្ចប់នៅក្នុងសភាពដើម ។

២- មិនត្រូវទុកដាក់ដោយច្របូកច្របល់ គឺត្រូវមានគោលការណ៍ " ចូលមុន ចេញមុន " ។

៣- ទុកដាក់ថ្នាំកសិកម្មនៅក្នុងកន្លែងដែលមានចាក់សោត្រឹមត្រូវ ។

៤- ទុកដាក់ថ្នាំកសិកម្មឱ្យឆ្ងាយពីចំណីអាហារ ភេសជ្ជៈ និងទឹកប្រើប្រាស់ ។

៥- មិនត្រូវទុកដាក់ថ្នាំកសិកម្មផ្ទាល់នឹងកម្រាលដី ឬឥដ្ឋទេ ត្រូវដាក់នៅលើកម្រាលឈើ ។

៦- កម្រាលថ្នាំកសិកម្មត្រូវឱ្យបានស្អាត និងមានសណ្តាប់ធ្នាប់ ដោយត្រូវទុកឱ្យមានចន្លោះខ្យល់ចេញចូលពីជួរមួយទៅជួរមួយទៀត ។

៧-នៅតាមមាត់ទ្វារ ឬច្រកចេញចូល មិនត្រូវឱ្យមានវត្ថុ ឬរបស់អ្វីដែលធ្វើឱ្យទើសទែងបង្ការពេលមានអាសន្ន ។

ខ- លក្ខខណ្ឌនៃការទុកដាក់ :

១- ចៀសវាងទុកដាក់ថ្នាំកសិកម្ម នៅកន្លែងដែលមានសីតុណ្ហភាពខ្ពស់ និងក្រោមពន្លឺថ្ងៃ ។

២- នៅក្នុងឃ្លាំង ត្រូវមានសភាពស្ងួត ។

៣-ត្រូវមានប្រព័ន្ធខ្យល់ចេញ ចូលបានល្អ ។

- ទីតាំងឃ្លាំងទុកដាក់ថ្នាំកសិកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដោយមានការឯកភាពពីក្រសួងបរិស្ថាន ។

## VII.២ ការដាក់តាំងលក់ថ្នាំកសិកម្ម

- ត្រូវដាក់តាំងលក់ថ្នាំកសិកម្មឱ្យមានរបៀបរៀបរយ ចៀសវាងការធ្លាក់បាក់បែកជាយថាហេតុ
- ត្រូវដាក់ផ្លាកនិមិត្តសញ្ញា " ប្រយ័ត្នគ្រោះថ្នាក់ " នៅក្នុងហាង
- ហាមដាក់តាំងលក់ថ្នាំកសិកម្មជិតចំណីអាហារ ថ្នាំពេទ្យ និងបរិក្ខារផ្សេងៗ ។

# VIII. ហាមការធ្វើអាជីវកម្មលក់ដូរ

## VIII.១ ថ្នាំកសិកម្ម

ហាមធ្វើអាជីវកម្មលក់ដូរនូវ :

១- ថ្នាំកសិកម្មក្លែងបន្លំ ។

២- ថ្នាំកសិកម្មក្រោមកម្រិតបមាណីគុណភាព ។

៣- ថ្នាំកសិកម្មហួសរយៈពេលប្រើប្រាស់ ឬខូចគុណភាព ។

៤- ថ្នាំកសិកម្មដែលពុំបានធ្វើការចុះបញ្ជិកា ឬបានចុះបញ្ជិកាហើយ តែពុំមានលេខបញ្ជិកានៅលើស្លាកសញ្ញា ។

៥- ថ្នាំកសិកម្មដែលបានចុះបញ្ជិកាស្ថិតក្នុងលក្ខខណ្ឌ ឬលិខិតអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ពិសោធន៍ ។

## VIII.២ ជីគីមី

ហាមធ្វើអាជីវកម្មលក់ដូរនូវ :

១- ជីគីមីក្លែងបន្លំ ។

២- ជីគីមីអន់គុណភាព ។

៣- ជីគីមីក្រៅយថាប្រភេទ ។

៤- ជីគីមីដែលពុំបានចុះបញ្ជិកា ឬបានចុះបញ្ជិកាហើយ តែពុំមានលេខបញ្ជិកានៅលើស្លាកសញ្ញា ។

បញ្ជាក់ :

ជីគីមីអន់គុណភាព អាចដាក់លក់បាន លុះត្រាមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងត្រូវផ្តល់ពត៌មានបន្ថែមអំពីប្រភេទ និងបរិមាណជីគីមីដែលនៅសល់នោះផង។ ជីគីមីទាំងនោះ ត្រូវវេចខ្ចប់ជាថ្មីដោយមានសរសេរអក្សរ " ជីគីមីអន់គុណភាព " និងសមាសភាគនៃធាតុចិញ្ចឹម (N-P-K)នៅលើបាវ ។

**VIII.៣ គ្រាប់ពូជ និងបំណែកពូជដំណាំ**

ហាមធ្វើអាជីវកម្មលក់ដូរនូវ :

១- គ្រាប់ពូជដែលធ្វើការបំរែបំរួលសែន ( GMO ) ។

២- គ្រាប់ពូជ និងបំណែកពូជដំណាំក្រោមកម្រិតបមាណីគុណភាពអប្បបរមា។

៣- គ្រាប់ពូជមានវិញ្ញាបនបត្រ ដែលពុំបានចុះបញ្ជិកា ឬចុះបញ្ជិកាហើយ តែពុំមានលេខបញ្ជិកានៅលើស្លាកសញ្ញា។

**VIII.៤ ចំណីសត្វ និងចំណីបន្ថែម**

ហាមធ្វើអាជីវកម្មលក់ដូរនូវ :

១- ចំណីសត្វ ឬចំណីបន្ថែមក្លែងបន្លំ ។

២- ចំណីសត្វ ឬចំណីបន្ថែមក្រោមកម្រិតបមាណីគុណភាព។

៣- ចំណីសត្វ ឬចំណីបន្ថែមខូចគុណភាព។

៤- ចំណីសត្វ ឬចំណីបន្ថែមដែលផុតកំណត់ប្រើប្រាស់ ។

៥- ចំណីសត្វ ឬចំណីបន្ថែមដែលពុំបានចុះបញ្ជិកា ឬបានចុះបញ្ជិកាហើយ តែពុំមានលេខបញ្ជិកាលើស្លាកសញ្ញា ។

## IX.ការផ្សព្វផ្សាយពាណិជ្ជកម្មថ្នាំកសិកម្ម

រាល់ការផ្សព្វផ្សាយថ្នាំកសិកម្មគ្រប់ប្រភេទទោះជាមធ្យោបាយណាក៏ដោយ ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានចុះបញ្ជិកាពេញលេញនូវថ្នាំកសិកម្មណាមួយរួចហើយ និងមានបំណងផ្សាយពាណិជ្ជកម្មថ្នាំកសិកម្មនោះ ត្រូវដាក់នូវអត្ថបទ ឬរូបភាពបញ្ចាំង ឬរូបភាពថ្នាំកសិកម្មទាំងនោះនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យ និងសម្រេចឯកភាពជាមុន មុននឹងធ្វើការផ្សព្វផ្សាយ ។

## X.ភារកិច្ចរបស់អាជីវករ

១- ត្រូវគោរពឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិ និងសេចក្តីណែនាំផ្សេងៗរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

២- ត្រូវបង្កលក្ខណៈងាយស្រួលដល់គ្រប់សកម្មភាពត្រួតពិនិត្យរបស់មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣- ត្រូវមានសៀវភៅកត់ត្រាស្ថិតិសម្ភារៈកសិកម្មចេញ ចូល និងស្តុកជាប្រចាំ ។

៤- ត្រូវដាក់តាំងបង្ហាញលិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារៈកសិកម្ម និងវិញ្ញាបនបត្រចុះបញ្ជិកាសម្ភារៈកសិកម្ម នៅក្នុងគ្រឹះស្ថានធ្វើអាជីវកម្មសម្ភារៈកសិកម្ម ។

## XI.សមត្ថកិច្ចគ្រប់គ្រង និងត្រួតពិនិត្យ

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចគ្រប់គ្រង ណែនាំ និងត្រួតពិនិត្យរាល់ការធ្វើអាជីវកម្មសម្ភារៈកសិកម្មក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង មានតួនាទីគ្រប់គ្រង ណែនាំ និងត្រួតពិនិត្យរាល់ការធ្វើអាជីវកម្មសម្ភារៈកសិកម្មនៅតាមខេត្ត ក្រុងរបស់ខ្លួន
- មន្ត្រីត្រួតពិនិត្យមានតួនាទីភារកិច្ច និងសិទ្ធិដូចខាងក្រោម :

  ១- ចូលត្រួតពិនិត្យក្នុងគ្រឹះស្ថាន និងបរិវេណគ្រឹះស្ថាន ឃ្លាំងស្តុក យានយន្តដឹកជញ្ជូន និងកសិដ្ឋានដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មសម្ភារៈកសិកម្មដែលសង្ស័យថាបានបំពានលើខ្លឹមសារអនុក្រឹត្យលេខ ៦៩ អនក្រ.បក ស្តីពីបមាណី និងការគ្រប់គ្រងសម្ភារៈកសិកម្ម ដោយសហការជាមួយរដ្ឋបាលឃុំ សង្កាត់ អាជ្ញាធរដែនដី ឬសមត្ថកិច្ចពាក់ព័ន្ធ ។

  ២- មានសិទ្ធិតម្រូវឱ្យអាជីវករបង្ហាញនូវសៀវភៅកត់ត្រាស្ថិតិចេញចូល និងស្តុក ឬឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មសម្ភារៈកសិកម្ម ។

  ៣- មានសិទ្ធយកសំណាកនៃផលិតផលសម្ភារៈកសិកម្មទាំងឡាយណាដែលសង្ស័យថាមានការបំពានលើបមាណីគុណភាពសម្រាប់ធ្វើការពិសោធ ។

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចផ្តន្ទាទោសពិន័យរដ្ឋបាល ដូចខាងក្រោម :

  ១- ព្រមានជាលាយលក្ខណ៍អក្សរ និងឃាត់ទុកវត្ថុល្មើសជាបណ្តោះអាសន្ន រួចរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើអាជីវកម្មសម្ភារៈកសិកម្ម :

  - ជីគីមីគ្រប់ប្រភេទ ទោះបីជីគីមីនោះបានមកពីការនាំចូល ឬការផលិតក្នុងស្រុកក៏ដោយ ដែលពុំបានចុះបញ្ជិកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ថ្នាំកសិកម្មដែលផលិត លាយផ្សំ វេចខ្ចប់ជាថ្មី នាំចូល លក់ដុំ ឬលក់រាយ ដែលមិនបានធ្វើការចុះបញ្ជិកា ឬពុំមានចែងក្នុងប្រកាសអនុញ្ញាតឱ្យប្រើប្រាស់ជាបណ្ដោះអាសន្នរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចំណីសត្វ និងចំណីបន្ថែមដែលផលិតក្នុងស្រុក នាំចេញ នាំចូល និងលក់ដូរក្នុងប្រទេស ពុំមានលក្ខណៈស្របតាមការចុះក្នុងបញ្ជិការួចហើយ ។

២- ព្រមានជាលាយលក្ខណ៍អក្សរ និងបង្ខំឱ្យធ្វើកិច្ចសន្យាកែតម្រូវក្នុងរយៈពេល ៧ ថ្ងៃ ចំពោះ :

- រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលមានបំណងផលិត នាំចូល ឬនាំចេញជីគីមីដែលពុំមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការវេចខ្ចប់ជាថ្មីនូវជីគីមីក្នុងថង់តូចៗសម្រាប់ដាក់លក់ដែលមិនមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ថ្នាំកសិកម្មដែលកំពុងត្រូវបានចរាចរនៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា តែពុំមានចែងក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ថ្នាំកសិកម្មដែលមានចែងក្នុងបញ្ជីអនុញ្ញាតឱ្យប្រើប្រាស់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តែពុំបានចុះបញ្ជិកា
- ថ្នាំកសិកម្មប្រភេទដែលស្ថិតក្នុងចំណាត់ថ្នាក់ទី I អនុលោមតាមចំណាត់ថ្នាក់អង្គការ WHO
- ថ្នាំកសិកម្មដែលបានធ្វើការចុះបញ្ជិការួច តែបានប្ដូររូបមន្ត ឬឈ្មោះពាណិជ្ជកម្ម
- ថ្នាំកសិកម្មក្លែងបន្លំ ខូចគុណភាព មានប្រភេទ ឬបរិមាណធាតុសកម្មខុសពីប្រភេទ ឬបរិមាណធាតុសកម្មដែលបានបញ្ជាក់លើស្លាកសញ្ញា
- ថ្នាំកសិកម្មដែលបានចែងក្នុងបញ្ជិកាស្ថិតក្នុងលក្ខខណ្ឌ ។

ឃាត់ទុកវត្ថុល្មើសជាបណ្ដោះអាសន្ន រួចរៀបចំសំណុំរឿងបញ្ជូនទៅតុលាការក្នុងករណីប្រព្រឹត្តល្មើសលើកទី ២ ។

៣-ព្រមានជាលាយលក្ខណ៍អក្សរ និងឃាត់ទុកវត្ថុល្មើសជាបណ្ដោះអាសន្ន រួចរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលបានធ្វើអាជីវកម្មសម្ភារៈកសិកម្ម :

- ជីគីមីដែលផលិត នាំចូល ឬលក់ក្នុងប្រទេសកម្ពុជា ដែលពុំមានសមាសភាគនៃសារធាតុចញ្ចឹមដូចគ្នាទៅនឹងការធានាគុណភាពដែលបានចុះបញ្ជិកា
- ជីគីមីក្លែងបន្លំ
- របៀប និងលក្ខខណ្ឌទុកដាក់ថ្នាំកសិកម្ម ដែលពុំអនុវត្តតាមការកំណត់ក្នុងសារាចរណែនាំនេះ
- ទីតាំងទុកដាក់ថ្នាំកសិកម្ម ពុំមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងពុំមានការឯកភាពពីក្រសួងបរិស្ថាន

- បែបបទ និងលក្ខខណ្ឌក្នុងផលិតកម្ម អាហ័រណកម្ម នីហ័រណកម្ម ពាណិជ្ជកម្មបសុឱសថ ដែលពុំតាមការកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសុខាភិបាល
- ចំណីសត្វ និងចំណីបន្ថែមដែលដាក់លក់មិនបានវេចខ្ចប់ និងគ្មានស្លាកសញ្ញាជាភាសាខ្មែរងាយយល់តាមទម្រង់ និងលក្ខណៈដែលកំណត់ក្នុងសារាចរណែនាំនេះ ។

ដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មជាស្ថាពរក្នុងករណីប្រព្រឹត្តល្មើសលើកទី ២ ។

៤- ព្រមានជាលាយលក្ខណ៍អក្សរ ហើយបង្ខំឱ្យធ្វើកិច្ចសន្យាកែតម្រូវ ក្នុងរយៈពេល ១៥ថ្ងៃ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើអាជីវកម្ម :

- ជីគីមីដែលគ្មានស្លាកសញ្ញាជាភាសាខ្មែរ ឬមានស្លាកសញ្ញាតែមិនអាចអានបានស្របតាមការកំណត់ក្នុងសារាចរណែនាំនេះ
- ថ្នាំកសិកម្មដែលវេចខ្ចប់ដោយសម្ភារៈវេចខ្ចប់ ពុំឆ្លើយតបទៅនឹងបមាណីដែលកំណត់ក្នុងសារាចរណែនាំនេះ
- ថ្នាំកសិកម្មដែលធ្វើការវេចខ្ចប់ជាថ្មីដោយពុំមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រាប់ពូជដំណាំដែលដាក់លក់ពុំបានវេចខ្ចប់ និងគ្មានស្លាកសញ្ញាតាមបមាណី និងយថាប្រភេទដែលកំណត់ក្នុងសារាចរណែនាំនេះ
- បសុឱសថដែលពុំមានលក្ខណៈសមស្របតាមបមាណីគុណភាពដែលកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសុខាភិបាល
- បសុឱសថ ចំណីសត្វ និងចំណីបន្ថែមក្លែងបន្លំ ក្រោមបមាណី ឬផុតកំណត់ប្រើប្រាស់ ។

ដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មជាបណ្ដោះអាសន្នក្នុងករណីប្រព្រឹត្តល្មើសលើកទី ២ ។

៥- ព្រមានជាលាយលក្ខណ៍អក្សរ ហើយបង្ខំឱ្យធ្វើកិច្ចសន្យាកែតម្រូវក្នុងរយៈពេល ៧ ថ្ងៃ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែល :

- បានបោះចោល បំផ្លាញចោលនូវសំណល់ ឬសម្ភារៈវេចខ្ចប់ថ្នាំកសិកម្មរបស់ខ្លួនដោយពុំមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងពុំមានការឯកភាពពីក្រសួងបរិស្ថាន
- ផ្សព្វផ្សាយថ្នាំកសិកម្ម ទោះតាមមធ្យោបាយណាក៏ដោយ ដែលពុំមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ដាក់លក់គ្រាប់ពូជ និងបំណែកពូជដំណាំក្នុងព្រះរាជាណាចក្រកម្ពុជា ពុំមានលក្ខណៈស្របតាមបមាណីគុណភាពដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មជាបណ្ដោះអាសន្ន ក្នុងករណីប្រព្រឹត្តល្មើសលើកទី ២ ។

៦- ព្រមានជាលាយលក្ខណ៍អក្សរ ហើយបង្ខំឱ្យធ្វើកិច្ចសន្យាកែតម្រូវក្នុងរយៈពេល ៧ថ្ងៃ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែល :

- ផលិតគ្រាប់ពូជមានវិញ្ញាបនបត្រ ឬបំណែកពូជដំណាំ ដើម្បីធ្វើពាណិជ្ជកម្ម ពុំបានធ្វើការចុះបញ្ជិកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ហើយពុំអនុវត្តតាមបច្ចេកវិទ្យាដែលបានណែនាំសម្រាប់ការផលិត និងដំណើរការរៀបចំទុកដាក់គ្រាប់ពូជទាំងនោះ
- នាំចូលគ្រាប់ពូជដំណាំ និងបំណែកពូជដំណាំពុំមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ទទួលបានសារាចរណែនាំនេះប្រធានគ្រប់នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគ្រប់ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង ត្រូវសហការជាមួយអាជ្ញាធរខេត្ត ក្រុង ដើម្បីធ្វើការផ្សព្វផ្សាយ និងអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០០២

រដ្ឋមន្ត្រី

ច័ន្ទ-សារុន

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ក្រសួងពត៌មាន
- ក្រសួងសុខាភិបាល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកសារ-កាលប្បវត្តិ